ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ❈ ៤៤

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ពិសេស ធទឧ

## សេចក្ដីជូនដំណឹង
## ស្ដីពីស្ថានភាពទឹកជំនន់ទន្លេមេគង្គ

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកទន្លេមេគង្គរួចមក ឃើញថា ឥទ្ធិពលព្យុះទី 9 ឈ្មោះ **រ៉ាម៉ាសាន់** ( ដូចដែលក្រសួងធនធានទឹក និងឧតុនិយមបានជម្រាបជូនកាលពីថ្ងៃទី 15 ខែកក្កដា ឆ្នាំ 2014 កន្លងមក) បានបង្កឱ្យមានភ្លៀងធ្លាក់យ៉ាងច្រើននៅអាងទន្លេមេគង្គ ក្នុងប្រទេសកម្ពុជា ឡាវ និងប្រទេសថៃ ។

ការធ្លាក់ភ្លៀងខាងលើនេះ បានធ្វើឱ្យទឹកទន្លេមេគង្គ បន្តហក់ឡើងជាបន្តបន្ទាប់ ។ យោងតាមការព្យាករណ៍កំពស់ទឹកជំនន់ទន្លេមេគង្គ បានបង្ហាញថា :

- ក្នុងរយៈពេលពី 3 ទៅ 4 ថ្ងៃខាងមុខ ទឹកទន្លេមេគង្គនៅខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តកំពង់ចាម អាចនឹងហក់ឡើង **ជិតដល់កម្រិតកំពស់ប្រកាសឱ្យមានការប្រុងប្រយ័ត្ន** ។
- ចំពោះទន្លេមេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់ ទឹកក៏នឹងបន្តហក់ឡើងជាបន្តបន្ទាប់ផងដែរ ។ ការបន្តហក់ឡើងនៃកំពស់ទឹកទន្លេនាពេលនេះ នឹងធ្វើឱ្យទឹកហូរចូលព្រែក និងលិចតំបន់ទំនាបតាមដងទន្លេមួយចំនួន នាំឱ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ និងដំណាំកសិកម្ម ។

ក្រសួងធនធានទឹក និងឧតុនិយម សូមអំពាវនាវដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ សូមមានវិធានការណ៍ និងបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ចំពោះស្ថានភាពទឹកជំនន់ខាងលើនេះ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១៤*

**រដ្ឋមន្ត្រី**

**លឹម គានហោ**